**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍កិច្ចប្រជុំ

# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែកក្កដា

**១. ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃព្រហស្បតិ៍ ៥រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤។

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)។

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

**៣.១-** ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៣.២-** សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៣៥រូប និងតាមប្រព័ន្ធអនឡាយចំនួន៣៧រូប សរុបចំនួន៧២រូប។

**៤. របៀបវារៈ៖**

**៤.១-**មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

**៤.២-** បទបង្ហាញស្តីពី បច្ចុប្បន្នភាពនៃការអនុវត្តការផ្តល់សេវាប្រិព(PrEP)នៅកម្ពុជា។ បង្ហាញដោយលោកវេជ្ជ. **កាអៀន ចិត្រា** អនុបណ្ឌិតផ្នែកជំងឺឆ្លង អនុប្រធានការិយាល័យបច្ចេកទេស និងជាប្រធានគ្រប់គ្រងទិន្នន័យ នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្រសួងសុខាភិបាល។

**៤.៣-** មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. លទ្ធផល ៖**

**៥.១-** ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែកក្កដា ឆ្នាំ២០២៤ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ដំណើរការនៃកិច្ចប្រជុំមាន៖

**ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បានមានប្រសាសន៍ជូនអង្គប្រជុំឱ្យបានជ្រាបថា កិច្ចប្រជុំថ្ងៃនេះ បានផ្តោតលើការប្រើប្រាស់ឱសថ ប្រិព(PrEP) ដែលជាថ្នាំការពារការចម្លងមេរោគអេដស៍ ដល់សមាជិក សមាជិកា បានយល់ដឹងពីការប្រើប្រាស់ និងបានផ្សព្វផ្សាយបន្តដើម្បីការពារការចម្លងថ្មី ដើម្បីឈានដល់គោលដៅ៩៥ ៩៥ ៩៥។ ការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ធ្វើឡើងជាពហុវិស័យ ដោយរួមបញ្ចូលទាំងផ្នែកសុខាភិបាល និងទាំងផ្នែកមិនមែនសុខាភិបាល ដែលតម្រូវឱ្យយើងបន្តប្រឹងប្រែងរួមគ្នាសម្រេចនូវគោលដៅដែលបានកំណត់ក្នុងគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាល ក្រោមមគ្គុទេសក៍ដ៏ខ្ពង់ខ្ពស់បំផុត សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

**៥.២- លោកវេជ្ជ. ការឿន ចិត្រា** អនុបណ្ឌិតផ្នែកជំងឺឆ្លង អនុប្រធានការិយាល័យបច្ចេកទេស និងជាប្រធានគ្រប់គ្រងទិន្នន័យ នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្រសួងសុខាភិបាល បានបង្ហាញពីបច្ចុប្បន្នភាពនៃការអនុវត្តការផ្តល់សេវាប្រិព(PrEP)នៅកម្ពុជា៖

- ស្ថិតិមេរោគអេដស៍នៅលើពិភពលោកឆ្នាំ២០២៣មានៈ អ្នកផ្ទុកមេរោគអេដស៍គ្រប់អាយុមានចំនួន ៣៩.៩លាននាក់ ករណីអ្នកឆ្លងមេរោគអេដស៍ថ្មីមានចំនួន ១.៣លាននាក់ ករណីស្លាប់ដោយសារមេរោគអេដស៍មានចំនួន ៦៣០.០០០នាក់ ករណីអ្នកផ្ទុកមេរោគអេដស៍ទទួលបាន ARV មានចំនួន ៣០.៧លាននាក់។ ចំពោះសមិទ្ធផលនៃការធ្វើតេស្តនិងការព្យាបាលគឺ អ្នកផ្ទុកមេរោគអេដស៍ដែលបានដឹងពីស្ថានភាពមាន ៨៦% អ្នកផ្ទុកមេរោគអេដស៍ដែលទទួលសេវាព្យាបាលមាន ៧៧% អ្នកផ្ទុកមេរោគអេដស៍ដែលមានបរិមាណមេរោគក្នុងឈាមថយចុះរហូតដល់កម្រិតទាបបំផុត ដែលមិនអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមាន ៧២%។
- ស្ថិតិមេរោគអេដស៍នៅក្នុងប្រទេសកម្ពុជាឆ្នាំ២០២៣មានៈ អ្នកផ្ទុកមេរោគអេដស៍មាន ៧៦.០០០ពាន់នាក់ អ្នកផ្ទុកមេរោគអេដស៍ដែលបានដឹងពីស្ថានភាពមាន ៨៩% អ្នកផ្ទុកមេរោគអេដស៍ដែលទទួលសេវាព្យាបាលមាន ៩៨% អ្នកផ្ទុកមេរោគអេដស៍ដែលមានបរិមាណមេរោគក្នុងឈាមថយចុះរហូតដល់កម្រិតទាបបំផុតដែលមិនអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមាន ៩៨% អត្រាប្រេវ៉ាឡង់មេរោគអេដស៍មាន ០.៥% ស្ត្រីបម្រើសេវាកម្សាន្តមាន ៤.៩% ក្រុមបុរសស្រឡាញ់បុរសមាន ៥.៥% ក្រុមបំប្លែងភេទមាន ១៣.៥% ក្រុមអ្នកជក់គ្រឿងញៀនមាន ៥.៧% ក្រុមអ្នកចាក់ថ្នាំញៀនមាន ១៥.២%។

តាមការពិនិត្យ និងពិភាក្សាលើការអនុវត្តការបង្ការនៃឆ្លងមេរោគអេដស៍តាមវិធីសាស្ត្រលេបថ្នាំបង្ការមុននៅពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍។ ប្រទេសកម្ពុជា បានចាប់ផ្តើមអនុវត្តសេវាផ្តល់ឱសថ PrEP ដោយឥតគិតប្រាក់នៅឆ្នាំ២០១៩ តាមរយៈឯកសារគោលគំនិតស្តីពីការអនុវត្តវិធីលេបថ្នាំបង្ការជាមុននៅពេលប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍នៅព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំដោយ ក្រសួងសុខាភិបាល នៅខែមីនា ឆ្នាំ២០១៩។ ការប្រើប្រាស់ឱសថនេះ ត្រូវបានផ្តល់អនុសាសន៍ដោយអង្គការ

សុខភាពពិភពលោក (WHO) គឺជាផ្នែកមួយនៃវិធីសាស្ត្របង្ការមេរោគអេដស៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ វិធីសាស្ត្រនេះមានសុវត្ថិភាពខ្ពស់ និងមានអត្រាភាពស៊ាំនឹងឱសថប្រឆាំងមេរោគអេដស៍កម្រិតទាប។ ប្រទេសលោកខាងលិចជាច្រើនរួមមាន៖ សហរដ្ឋអាមេរិក អង់គ្លេស បារាំង បែលហ្ស៊ិក និងហូឡង់ បានយល់ស្របតាមអនុសាសន៍អង្គការ WHO និងបានដាក់បញ្ចូលការបង់ថ្លៃសេវា PrEP ទៅក្នុងសេវាធានារ៉ាប់រងសុខភាព ឬការបង់ថ្លៃដោយខ្លួនឯង៕

**ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** បានធ្វើការបញ្ជាក់ថា កិច្ចសហការរវាងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ នៃក្រសួងសុខាភិបាល រួមនិងអង្គការយូអិនអេដស៍ (UNAIDS) បានសង្កេតឃើញថាក្នុងទិន្នន័យនៃអ្នកឆ្លងមេរោគអេដស៍ថ្មីមានការថយចុះ។ កម្ពុជាបានកាត់បន្ថយការចម្លងថ្មីនៃមេរោគអេដស៍ឆ្នាំ២០២២ មាន១.៤០០នាក់ ក្នុងឆ្នាំ២០២៣ មាន១.៣០០នាក់ និងឆ្នាំ២០២៤ មាន១.២០០នាក់ ចំណែកចំនួនអ្នកស្លាប់ មាន១.១០០នាក់(ឋិតនៅក្នុងចំនួនដដែល) ជាពិសេសដោយមានការយកចិត្តទុកដាក់ និងទប់ស្កាត់ចំពោះការឆ្លងមេរោគអេដស៍ពីម្តាយ ទៅកូនមានការថយចុះ។ បើទោះបីជាយើងទទួលបានភាពជោគជ័យ ប៉ុន្តែយើងក៏នៅមានកត្តាប្រឈមមួយចំនួន ជាពិសេសក្រុមប្រជាជនគន្លឹះនៅតែជាបញ្ហាដដែលពុំទាន់មានការប្រែប្រួល។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារបង្ការ គឺជាយុទ្ធសាស្ត្រចម្បងក្នុងការងារសុខភាពសាធារណៈ ហើយក៏ជាមូលដ្ឋានគ្រឹះក្នុងការឆ្ពោះទៅសម្រេចនូវគោលដៅការគ្របដណ្តប់សុខភាពសកល។ **ឯកឧត្តមបណ្ឌិត** បានជំរុញលើកទឹកចិត្តឱ្យសមាជិកក្រុមប្រឹក្សាបច្ចេកទេសដែលអនុវត្តផ្ទាល់លើការងារអេដស៍ លើកពីបទពិសោធន៍រួមជាមួយនឹងឧបសគ្គនានា ក្នុងការអនុវត្តការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីរកវិធីសាស្ត្រឆ្លើយតបឱ្យបានទាន់ពេល និងមានប្រសិទ្ធភាពខ្ពស់។

សម្រាប់កិច្ចប្រជុំបន្ទាប់នឹងកំណត់យក នៅថ្ងៃសុក្រ ៤រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ (Zoom)៕

ថ្ងៃអង្គារ ១០រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤

**ប្រធានអង្គប្រជុំ**

**បណ្ឌិត ឈឹម ឃិនដារ៉េត**

**បានពិនិត្យត្រឹមត្រូវ**

**ប្រធាននាយកដ្ឋាន ទ.ច.ប.ធ**

**វេជ្ជ.ហួត សេរីវង្ស**

អ្នកធ្វើរបាយការណ៍

**ស៊ុំ ផល្លា**